

ឧបសៅ សង្ឃា

# អញ និង យើង ?



ការសាកល្បងពិចារណា

## មាតិការឿង

អារម្ភកថា ........ 2
មនោគមវិជ្ជា នៃសម្តេចសីហនុ ........ 4
សេចក្តីសន្និដ្ឋាន ........ 9

# អារម្ភកថា

គេអាចនិយាយបានថា គំនិត វាបំផុះ នូវចរិត, តែចរិតក៏វា បង្ខឹក នូវគំនិតដែរ។ នៅចំពោះមុខស្ថានភាព កើតឡើងមួយ តម្រូវឱ្យមនុស្ស ការពារប្រយោជន៍អ្វីមួយ ដែលខ្លួន មានការជំពាក់ចិត្ត ដែលវានាំបំផុះ នូវមតិ ឬ អកប្បកិរិយា របស់ខ្លួន។ តែ ការបំផុះនោះ វាចាំបាច់ឱ្យត្រូវនឹងទំនង នៃការវិវត្តន៍សង្គម ដែលវាបង្ខំ ឱ្យមានការរំលេចនៃកម្លាំងប្រឆាំងថ្មីនឹងប្រយោជន៍ ដែលត្រូវការពារ។ ការវិវត្តន៍សង្គមនេះឯង ដែលវាមានឥទ្ធិពល ទៅលើការបង្កើត នៃចរិតនយោបាយ សំរាប់តស៊ូ ដើម្បី ការពារមនោគមវិជ្ជា (idéologie)។ តែជួនកាល ចរិតផុះឡើងនោះ វាផ្ទុយស្រឡះពីចរន្ត នៃការវិវត្តន៍សង្គម ព្រោះ វាកើតពី ផលិផលបញ្ញា នៃភារៈបរិសុទ្ធ របស់បុគ្គល ដែលខ្លួនបានសេពគប់ជាមួយក្រុមមួយ ដែលជាអ្នកបង្កើត មនោគមវិជ្ជា ហើយផ្សាយជាគំនិត។ វាមានការខុសគ្នា រវាងប្រព័ន្ធ នៃគំនិត របស់អ្នកបង្កើត ដែលហៅថាទ្រឹស្ដី (théorie) ដែលគាត់តែងឡើង នៅក្នុងអណ្ដាប់ នៃការប្រតិបត្តិ និង « មនោគមវិជ្ជា » ដែលស្ថិតនៅ ជាការកំណត់សុទ្ធសាត។ ដូច្នោះ មនោគមវិជ្ជា វាជាប្រព័ន្ធ មានភាពមាំមួន អាចផ្លាស់ប្ដូរ ដែល សំដែង ពន្យល់ ឬ បង្ហាញនូវចរិត នៃមនុស្ស ចំពោះលោកិយ ដែលជាលោក មាន

ការវិវត្តន៍ ជានិច្ច។ គេអាចនិយាយបានថា ទ្រឹស្តី វាជាគំនិត ដែលគេយកមកអនុវត្ត ចំណែកឯ មនោគមន៍វិជ្ជា វាជាមូលដ្ឋានគ្រឹះ នៃគំនិតមាំមួន អាចប្តូរបានពិតទៅតាមការវិវត្តន៍សង្គម តែគ្រឹះគំនិត វាស្ថិតនៅជានិច្ចជាគតិបណ្ឌិត នៅក្នុងសង្គមក្រែប្រែលំនាំមួយ។ ឧទាហរណ៍ មនោគមវិជ្ជា នៃលទ្ធិកុម្មុយនិស្តចិនសព្វថ្ងៃ វាដូរអត្តរូប គឺទ្រឹស្តី នៃការអនុវត្ត នៃសេដ្ឋកិច្ចសេរី ដើម្បី ឆ្លើយនឹងការចាំបាច់ នៃលោកូបនីយកម្ម និង សេដ្ឋកិច្ចផ្សារ តែនៅរក្សាអត្តរស់ នៃមនោគមន៍កុម្មុយនិស្ត ទោះបីមានការកែប្រែលំនាំអាការៈក្រៅ តែ នៅរក្សាគ្រឹះគំនិតជានិច្ច គឺប្រឆាំងនឹង អនុត្តរភាព នៃលោកខាងលិច, សហរដ្ឋអាមេរិក, ការតស៊ូវណ្ណៈ, ការជំទាស់ នៃលទ្ធិប្រជាធិបតេយ្យ និង គោលការណ៍ នៃសិទ្ធិមនុស្ស នៃលោកខាងលិច។ វាពិតជាគ្មានវិមតិ ឬ ការសង្ស័យ ថាវាមាន មនោគមវិជ្ជាគ្មានបំលាស់ប្តូរទាល់តែសោះនោះឡើយ ឬ គោលលទ្ធិ (doctrine) នៃការបំលាស់ប្តូរ ដែលមិនកំណត់ដោយច្បាស់លាស់ នូវសណ្តាប់ធ្នាប់សង្គម តែការបំលាស់ប្តូរនោះ វាអាចប្រែប្រួលរៀងខ្លួនពីដើមដល់ចុង បើមនោគមវិជ្ជា និង គោលលទ្ធិនោះ វាជាសត្រូវបំផ្លាញមនុស្សជាតិ ដូចយ៉ាង គោលលទ្ធិ នៃណាហ្ស៊ី តែមនោគមវិជ្ជានេះ វានៅលាក់ខ្លួន នៅក្នុងគោលលទ្ធិជ្រុលនិយម ដែលកំពុងផុះ

ឡើងវិញលើលោកនេះ ដោយលើកយក នូវគំនិតជាតិនិយមបរិសុទ្ធ មកធ្វើគោលគំនិត។

## មនោគមវិជ្ជា

ក្រោយពីស្រុកខ្មែរ ទទួលបានឯករាជ្យ នៅទសវត្សរ៍៥០ ពេលនោះ មានកើត គណបក្សនយោបាយមួយចំនួន គ្រប់គ្រងដោយរដ្ឋជម្មនុញ្ញ ធ្វើការប្រកួតនយោបាយគ្នា ដើម្បី ដណ្ដើមកៅអី នៅក្នុងរដ្ឋសភាជាតិ។ គណបក្សនិមួយៗសុទ្ធតែមាន ទ្រឹស្ដី បង្ហាញនៅក្នុង កម្មវិធីនយោបាយខុសៗគ្នា តែមិនមានមនោគមន៍វិជ្ជា ព្រោះ មនោគមវិជ្ជា វាកើតចេញពី មធ្យោបាយស្ថាប័នផង និង ច្រើនតែមធ្យោបាយនរជាតិផង ដែលមានរៀបចំនៅក្នុងសង្គម តែថាសង្គមខ្មែរ គ្មានមធ្យោបាយទាំងឡាយនោះ សំរាប់ធ្វើឱ្យលូតលាស់ នូវមនោគមន៍វិជ្ជា ដោយហេតុថា រាជានិយមបុរាណខ្មែរ គ្មានលក្ខណ: ជាស្ថាប័នជាតិនោះឡើយ ព្រោះជា វេទី នៃវណ្ណៈ សំរាប់រាស្ត្រ គោរពបូជា ស្មើនឹងអាទិទេព ហើយគ្របសង្កត់លើប្រជារាស្ត្រ ដោយអំណាចសម្ភារ: ព្រមទាំងអំណាចចេត្រ[1]ដ៏មហិទ្ធានុភាព។ សង្គមបែបនេះ មិនអនុគ្រោះ ឱ្យមានកើត នូវមនោគមន៍វិជ្ជាអ្វី ក្រៅពី កំណោត នៃបុគ្គល[2] ចំពោះព្រះមហាក្សត្រតែប៉ុណ្ណោះ។ ពុម្ពសង្គមនេះឯង ដែលវាផ្ដិតចេញជា គណបក្សនយោបាយ

[1] អំណាចចេត្រ : pouvoir spirituel។
[2] កំណោតនៃបុគ្គល : culte de personnalité។ កំណោត គឺ សេចក្ដីកោត។

ដែលសុទ្ធតែមាន កំណោត នៃបុគ្គល ហើយគ្មាន មនោគមន៍វិជ្ជា ឬគោលលទ្ធិអ្វីច្បាស់លាស់នោះឡើយ។ ជួនកាលរហូតយកឈ្មោះ មេគណបក្ស មកដាក់ឈ្មោះឱ្យគណបក្សតែម្តង ឬ សំគាល់គណបក្ស តាមឈ្មោះមេគណបក្ស។ គេថាធ្វើបែបនេះ គឺសំរាប់ឱ្យរាស្ត្រស្រួលចំណាំ ដូចយ៉ាងយកលេខរៀង ឬ រូបសញ្ញា របស់គណបក្ស សំរាប់ឱ្យអ្នកបោះឆ្នោត គាត់ស្រួលជ្រើសរើស។ តែខណៈនោះ វាជានិយម គេបង្កើតប្រវត្តិសាស្ត្រជាតិ ដើម្បី បំពេញកង្វះ នូវមនោគមវិជ្ជាវណ្ណៈ ដោយយកតួអង្គព្រះមហាក្សត្រ ជាមនោគមន៍វិជ្ជាជាតិ[3] ព្រោះ គេផ្អែកលើ ហេតុបច្ច័យ ថា ព្រះមហាក្សត្រជាអ្នកដឹកនាំជាតិកំពូល និង ជានិមិត្តរូប នៃសាមគ្គីជាតិ និង ឯកភាពជាតិ, ជួនរហូតទុកជា បិតាជាតិតែម្តង ព្រោះព្រះអង្គ ជាអ្នកបីបាច់ថែរក្សាប្រជារាស្ត្រ។ តែរវាងឥរិយាបថ របស់ព្រះមហាក្សត្រ ជាអ្នកផ្តាច់ការនិយមតាមឧបាទាន នៃវណ្ណៈអំណាច និង មនោគមវិជ្ជានៃសេចក្តីស្នេហាបង្កើតឡើងនោះ វាមានការរមួល ព្រោះវាគ្រាន់តែជាទ្រឹស្តីនយោបាយ យកមកអនុវត្ត សំរាប់បំរើប្រយោជន៍បុគ្គល។

[3] បង្កើតប្រវត្តិសាស្ត្រ និង សរសេរប្រវត្តិសាស្ត្រ វាមិនដូចគ្នានោះឡើយ គឺថា ទី១ គឺព្រឹត្តិការណ៍ ដែលមានកើតឡើងនៅក្នុងសង្គមជាតិ មកបង្កើតជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាតិ ដើម្បីបំរើប្រយោជន៍អ្វីមួយដែលអ្នកបង្កើតចង់បាន។ ចំណែក សរសេរប្រវត្តិសាស្ត្រ គឺ កត់ចំណាំទុក ព្រឹត្តិការណ៍អ្វីមួយ ដោយគ្មានធ្វើការវិនិច្ឆ័យនោះឡើយ។

នៅស្រុកខ្មែរ ក្នុងទស្សវត្ស ៥០ ក្នុងសង្គ្រាមត្រជាក់ រវាង លោកសេរី និង លោកកុម្មុយនិស្ត សពសម្តេចសីហនុ ទ្រង់ សាកល្បងបង្កើត មនោគមវិជ្ជាជាតិមួយ ដើម្បី បង្កើត អព្យាក្រឹតភាពខ្មែរ នៅចំពោះមុខទំនាស់ នៃលោកទាំង ពីរ ហើយ នៅក្នុងនយោបាយផ្ទៃក្នុងខ្មែរ ដើម្បី ដោះស្រាយ ទំនាស់ទ្រឹស្តី រវាង ពួកអ្នកស្តាំនិយម និង ពួកអ្នកឆ្វេង និយម។ ព្រះអង្គ ឱ្យឈ្មោះមនោគមវិជ្ជាថា « សង្គមរាស្ត្រ និយម »។ ផលនៃកុសល នៃការបង្កើតនេះ ដែលព្រះអង្គ ខ្លួនឯង តែងបន្លួនជាមោទនភាព នៅលើឆាកអន្តរា ជាតិផង និង ជាតិផង ថាវាជា រាជតម្រិះប្រកបដោយ ទេពកោសល្យ អាចធ្វើឱ្យស្រុកខ្មែរ មានសន្តិភាព នៅក្បែរ សង្គ្រាមយៀកណាម ដែលជាជម្លោះដោយអាវុធ រវាងសហ រដ្ឋអាមេរិក និង លោកកុម្មុយនិស្ត ដោយយកយៀកណាម ជាចន្លោះសមរភូមិ។ បើឃើញតែនាមភ្លាម វាហាក់បីជា ការពិត ព្រោះស្រុកខ្មែរ គ្មានសង្គ្រាម តែសម្តេចសីហនុ ព្រះអង្គភ្លេចគិតថា ទោះបីសហរដ្ឋអាមេរិក មិនទទួល ស្គាល់អព្យាក្រឹតខ្មែរជាផ្លូវការ តែសហរដ្ឋអាមេរិក គោរព នូវបូរណភាពទឹកដីខ្មែរ នៅក្នុងលក្ខខណ្ឌ ដែលខ្មែរ អនុ វត្តពិតប្រាកដ នូវជំហរ នៃអព្យាក្រឹតភាព ដែលខ្លួនបាន ប្រកាសជាឯកតោភាគី។ លក្ខខណ្ឌតម្រូវដោយសហរដ្ឋអា មេរិកនេះឯង ដែលសម្តេចសីហនុ ទ្រង់បំពានដោយខ្លួន ឯង ដោយអនុញ្ញាត ឱ្យកងទ័ពយៀកកុង ដែលជាសត្រូវ

នឹងសហរដ្ឋអាមេរិក មកតាំងទីទ័ព នៅក្នុងស្រុកខ្មែរ ដើម្បី ធ្វើសង្គ្រាមប្រឆាំងនឹង សហរដ្ឋអាមេរិក និង យៀកណាមខាងត្បូង។ ដូច្នោះ អព្យាក្រឹត ដើម្បីសន្តិភាព របស់សម្តេចសីហនុ វាជាសំដីមោឃៈ ហើយ លែងមានបច្ច័យ ដែលនាំឲជឿបានលើឆាកអន្តរជាតិ និង ជាតិ។ ដូច្នេះ មនោគមវិជ្ជា នៃសង្គមរាស្ត្រនិយម របស់ព្រះអង្គ វាក៏រវាតបន្តិចម្តងៗ លើឆាកនយោបាយនៅក្នុងផ្ទៃប្រទេស ដែលនាំបញ្ចេញ ឱ្យឃើញ តែអំពើផ្តាច់ការ របស់ព្រះអង្គ សំរាប់តែរក្សាអំណាចតែប៉ុណ្ណោះ ព្រោះ ស្រុកខ្មែរ ជាកោះសន្តិភាព ប្រកាសដោយសម្តេចសីហនុ វាប្រែក្លាយទៅជា កោះគុក សំរាប់អ្នកមានមតិខុសពីព្រះអង្គ គ្រប់និន្នាការនយោបាយ។ លុះមកដល់ទសវត្ស ៦០-៧០ មនោគមវិជ្ជា របស់សម្តេចសីហនុ វាមិនគ្រាន់តែលែងមាន ឥទ្ធិពលទៅលើប្រជារាស្ត្រ វាថែមទាំងទៅជា គ្រោះថ្នាក់ ដល់ប្រជាជាតិ ព្រោះទឹកដីខ្មែរ ត្រូវបានកងទ័ពយួនកុម្មុយនិស្ត ប្រមាណ ៦ម៉ឺននាក់ចូលមកកាន់កាប់ ដែលនាំឱ្យសហរដ្ឋអាមេរិក មានប្រតិកម្មសំរាប់ការពារ ដោយទំលាក់គ្រាប់បែក ជាចម្លើយ ទៅលើទីតាំងទ័ពនោះ ដែលនាំឱ្យរាស្ត្រខ្មែរ រស់នៅក្បែរដំបន់នោះ ទទួលរងគ្រោះ ជាញឹកញយ។ នៅចំពោះស្ថានភាពនេះ សម្តេចសីហនុ ទ្រង់មិនព្រម ទទួលស្គាល់ថា នយោបាយ របស់ទ្រង់ វាកំពុងដើរខុស តែបែរជាទុក ខ្មែរឆ្វេងនិយមក្តី ស្តាំងនិយមក្តី និង ជាតិនិយមក្តី ជាអ្នក

រងកំហុស រហូតឱ្យតុលាការសឹក កាត់ទោសប្រហារជីវិត ឬ បញ្ជាឱ្យសម្លាប់ ជាសម្ងាត់ជនខ្មែរណា ដែលទ្រង់ ទុកជាសត្រូវ ដោយថាហេតុនឹងព្រះអង្គ។ រាជប្រតិកម្មអវិជ្ជមាននេះ មិនត្រឹមតែបំផ្លាញអព្យាក្រឹតភាពខ្មែរ លើឆាកអន្តរជាតិ គឺថែមទាំង កំទិច នូវសិទិទ្ធពលជាតិ ដែលនាំឱ្យយួនកុម្មុយនិស្ត ឆ្លៀតទាញយកប្រយោជន៍ ដោយប្រើកំហុស របស់សម្តេចសីហនុ ជាទ្រព្យសកម្ម របស់គេ។ អព្យាក្រឹតភាព នៅលើតែបបូរមាត់ និង ការចាកភេទ ជាអ្នកដឹកនាំ មាន សីលធម៌ នៃសម្តេចសីហនុ នេះឯងដែលនាំឱ្យស្រុកខ្មែរ ដើរចូលទៅក្នុងយុទ្ធសាស្រ្ត លោកកុម្មុយនិស្ត នៅតំបន់ឈ្លូចិន ដែលមាន ចិន និង យួនក្រហមជាអ្នកគ្រប់គ្រងនយោបាយខ្មែរ នាំឱ្យសង្គ្រាម នៅស្រុកយួន ឆាបឆេះសន្ធោរសន្ធៅ ចូលមកក្នុងស្រុកខ្មែរ នៅឆ្នាំ ១៩៧០។ អតិតៈនេះឯង វាបង្កើត ពួកខ្មែរក្រហមរណបយួន និង ស្ថានភាព នៃស្រុកខ្មែរបច្ចុប្បន្ន ដែលជាកោះសន្តិភាព សំរាប់ ពួកចិនពាល ឬ ម៉ាហ្វីយ៉ា និង យួនកុម្មុយនិស្ត គេនាំទុក្ខវេទនាគ្រប់បែបយ៉ាង មាននាមជាការអភិវឌ្ឍន៍ជាតិ មកឱ្យប្រជាពលរដ្ឋខ្មែរ ឱ្យមានការភាន់ភ្លេកថា ស្រុកខ្មែរមានការលូតលាស់ ខាងផ្នែកសម្ភារៈសម័យ ដែលពួកខ្មែររណបយួន ជាពួកអ្នកដឹកនាំ គេថាជាឋានសួគ៌ សំរាប់គ្រួសារ របស់គេ។

# សេចក្តីសន្និដ្ឋាន

មនោគមវិជ្ជា របស់សម្តេចសីហនុ ហៅថា « សង្គមរាស្ត្រនិយម » ដែលទ្រង់ទុកជាផ្លូវកណ្តាល ដែលវាអាចនាំឱ្យប្រជារាស្ត្រខ្មែរ ជួបនូវភាពត្រជាក់ត្រជុំ សុខដុមរមនា ជាការគិតមួយ ទំនងជាមាន សុទ្ធចិត្ត និង សុភនិច្ឆ័យ តែព្រះអង្គគ្មានបញ្ញាគ្រប់គ្រាន់ សំរាប់ធ្វើឲបានសម្រេច នូវគំនិត របស់ព្រះអង្គ ព្រោះទ្រង់ គ្មានជញ្ជីងសំរាប់ថ្លឹង អាត្មា (moi) និង យើង (nous)។ ភាព នៃអាត្មា របស់ព្រះអង្គមានធម្មជាតិ ជា អញ ដែលវាផ្ទុយស្រឡះពីអនោគមវិជ្ជានៃទ្រង់ ដែលត្រូវមានចាំបាច់ ជាគោលការណ៍ នៃ « យើង » ដែលជាគោលដៅ សំរាប់សង្រួបសង្រួម និង នាំបង្កើត នូវអំពើរួម ដែលជាកម្មវិធីរួម សំរាប់ជោគជ័យ នៃការអនុវត្តន៍រួម។ យើង ជា របស់ថ្មី សំរាប់ប្រជាជាតិខ្មែរដែលត្រូវចាំបាច់ មានជំនឿ និង មានសេចក្តីទុកចិត្តលើអំពើរួម ដែលត្រូវធ្វើ ជួនកាលវាអាចជួបប្រទះ នូវអពើដែលមិនបានគ្រងទុក តែបើអ្នកធ្វើ មានជំនឿរួម និងសេចក្តីទុកចិត្តគ្នា វានឹងអាចរកមធ្យោបាយ ដោះស្រាយគ្រប់បញ្ហា ដែលមានកើតឡើងដោយមិនបានគិតទុក។ តែ អញ នៃសម្តេចសីហនុ វាស្ថិតនៅលើ និច្ចលភាព ព្រោះវាជាទម្លាប់ របស់រាជានិយមផ្តាច់ការខ្មែរ។ ទំនាស់ រវាងអញ នៃសម្តេចសីហនុ និង យើង នោះឯង ជាបរាជ័យរបស់សីហនុ។

ស្រុកខ្មែរ ជាប្រទេសតូចណាស់ រស់នៅក្បែរប្រទេសជិតខាង ដែលគេមាន មធ្យោបាយ ទាំងជនជានមនុស្ស និង សម្ភារៈគ្រប់គ្រាន់ សំរាប់ស្វែងរកប្រយោជន៍ របស់គេនៅស្រុកខ្មែរ។ បើអ្នកដឹកនាំខ្មែរ គ្មានបញ្ញា សំរាប់ការពារប្រយោជន៍ជាតិ និង ធ្វើកំហុស នយោបាយដឹកនាំជាតិ គឺច្បាស់ជា ពុំអាចនឹងងាយកែសម្រួលបានវិញនោះឡើយ។ សព្វថ្ងៃ បើប្រជាពលរដ្ឋខ្មែរ និង អ្នកដឹកនាំជាតិ មិននាំគ្នាឱ្យតម្លៃទៅ « យើង » និង « ការទទួលខុសត្រូវរួម » នៅមុខបញ្ហាជាតិ ដើម្បីរកមធ្យោបាយដោះស្រាយ គឺពិតជាស្រុកខ្មែរ មិនគ្រាន់តែជាប្រទេសតូច គឺថែមទាំងជាប្រទេសខ្ញុំគេ។ ដូច្នេះ ស្រុកខ្មែរ ត្រូវចាំបាច់ មានអ្នកដឹកនាំ មានបញ្ញា យក « យើងជាខ្មែរ » ជាគោលការណ៍ដឹកនាំជាតិ ដើម្បី ប្រយោជន៍ជាតិ មិនមែនយក « អញ » ដើម្បី បំរើប្រយោជន៍អញនោះឡើយ។ ទំនាស់ រវាង ហ៊ុន សែន និង សម រង្ស៊ី ជាទំនាស់ អញ និង យើង។ ហើយនៅពេលណាអ្នកទាំងពីរ ត្រូវគ្នាម្តងៗ គឺគាត់ឈរលើគោលការណ៍ « យើង ជា អញ » មិនមែន « យើងជាខ្មែរ » នោះទេ ដើម្បី ចែកប្រយោជន៍គ្នាតែប៉ុណ្ណោះ ហើយ ការបែកចែកប្រយោជន៍គ្នា នៅក្នុងការគិតថា « យើង ជា អញ » នេះឯង ដែលវាគ្មានដំណោះស្រាយ សំរាប់ប្រយោជន៍ជាតិរហូតមកដល់សព្វថ្ងៃ៕